# យេម៉ែន

## សេចក្តីសង្ខេបការជួយជនរងគ្រោះក្នុងប្រទេស

### សូចនាករប្រទេស

- **រយៈពេលមានជម្លោះនិងការប្រើប្រាស់គ្រាប់មីន/កាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមៈ** ប្រទេសយេម៉ែន មានមីន និង កាកសំណល់ពិសង្គ្រាម ជាពិសេសនៅភាគខាងត្បូងនិងចន្លោះ ព្រំដែលខាងជើង និង ខាងត្បូង ដោយសារជម្លោះតាំងពីឆ្នាំ ១៩៦២ (១៩៦២-១៩៧៥ នៅខាងជើង ហើយ ១៩៦៣-១៩៦៧ និង ១៩៧០-១៩៨៣ ជម្លោះទ័ពព្រៃនិយមឆ្វេង។ ១៩៩៤សង្គ្រាម បំបែករដ្ឋ តាំងពីឆ្នាំ២០០៤ មកពួកស៊ីអីតបះបោះនៅខាងភាគជើង [១]។
- **ការប៉ាន់ប្រមាណពីការប៉ះពាល់ៈ** មកដល់ខែសីហាឆ្នាំ២០០៨ បានប៉ាន់ប្រមាណថាផ្ទៃដី ២៤៣ គ.ម[២] សង្ស័យថាមានមីននិងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម [២]។
- **សន្ទស្សន៍អភិវឌ្ឍធនធានមនុស្សៈ** ឈរលំដាប់ទី១៥៣ ក្នុងចំណោម ១៧៩ ប្រទេស ការអភិវឌ្ឍន៍មនុស្សនៅទាប (បើប្រៀបធៀបទៅនឹងប្រទេសលំដាប់ទី ១៤៩ នៅក្នុងឆ្នាំ ២០០៤) [៣]។
- **ចំណូលជាតិសរុប (តាមវិធីសាស្ត្រ អាទូស)ៈ** ៩៥០ លានដុល្លា — លំដាប់ទី ១៦៩នៃប្រទេស ២១០ (ប្រៀបធៀបទៅនឹង ៦១៥ លានដុល្លានៅក្នុងឆ្នាំ ២០០៤) [៤]។
- **អាត្រាគ្មានការងារធ្វើៈ** ៣៥%(៣៥%បើប្រៀបធៀបនៅក្នុងឆ្នាំ២០០៤) [៥]
- **ធនធានខាងក្រៅសម្រាប់ថៃទាំសុខភាព គិតជាភាគរយនៃចំណាយសរុបៈ** ២៤.៦%(ប្រៀបធៀបឆ្នាំ ២០០៤ មាន១៥%) [៦]។
- **ចំនួនអ្នកថៃទាំសុខភាពអាជីពៈ** ១០នាក់ក្នុងចំនួនប្រជាជន ១០០០០នាក់ [៧]
- **ស្ថានភាពអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការៈ** យេម៉ែនបានផ្តល់សច្ចានុប័នអនុសញ្ញា និង ពិធីសារនៅថ្ងៃទី ២៦មិនាឆ្នាំ២០០៩ [៨]
- **ថវិកាចំណាយលើវិស័យពិការភាព** :មិនដឹង។ កម្មវិធីជំនួយជនរងគ្រោះបានទទួលមូលនិធិពីរដ្ឋាភិបាល (ត្រូវគ្នាជាមួយនឹងមូលនិធិអន្តរជាតិ តែវាមិនគ្រាប់គ្រាន់ទេ ហើយបានផ្តាច់អស់នៅក្នុងឆ្នាំ ២០០៨។
- **ការវាស់វែងអំពីភាពក្រីក្រ និង ការអភិវឌ្ឍន៍ៈ** យេម៉ែនជាប្រទេសក៏ក្រីក្របំផុតមួយនៅមជ្ឈឹមបូពា ពឹងអាស្រ័យលើធនធានប្រេងដែលកំពុងថយចុះ។ ប្រជាជន៤៥%រស់នៅក្រោមបន្ទាត់ក្រីក្រ។ ហើយការអភិវឌ្ឍន៍ត្រូវបានរារាំងដោយកំណើនប្រជាជនដ៏លឿន និងកំណើនគ្មានការងារធ្វើ។ បើទោះជាប្រទេសមួយនៅក្នុងចំណោម "ប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុតក្តី" ក៏ប្រទេសនេះនៅតែទទួលបានជំនួយអភិវឌ្ឍតិចតួចរហូតមកទល់ការប្រកាសអោយប្រើផែនការជំនួយ៥ពាន់លានដុល្លានៅក្នុងឆ្នាំ២០០៦ ដើម្បីជួយអោយយេម៉ែនសម្រេចបានគោលដៅសហសវត្សន៍របស់ខ្លួន។ បើទោះជាយ៉ាងនេះក្តី ក៏ខ្លួនមិនអាចសម្រេចបានទាំងអស់ដែរតែប្រហែលជាបានដល់គោលដៅមួយ [៩]។

| ចំនួនសរុបនៃអ្នករងគ្រោះថ្នាក់ដោយសារមីន/សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ចាប់ពីឆ្នាំ១៩៦២: យ៉ាងតិច ៥០៦៨នាក់ | | | |
|---|---|---|---|
| ឆ្នាំ | ចំនួនសុរប | ស្លាប់ | របួស |
| ២០០៤ | ១៨ | ៩ | ៩ |
| ២០០៥ | ៣៥ | ៩ | ២៦ |
| ២០០៦ | ១៨ | ៧ | ១១ |
| ២០០៧ | ២៦ | ៥ | ២១ |
| ២០០៨ | ២២ | ១០ | ១២ |
| សរុបរួម | **១១៩** | ៤០ | **៧៩** |

- **ចំនួនប៉ាន់ស្មាននៃអ្នករស់រានពីគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមៈ** មិនដឹង។ តែយ៉ាងហោចណាស់ក៏មាន ២ ៤៤៥ នាក់ដែរ។
- **ស្ថាប័នសម្របសម្រួល/ក្រុមបង្គោលជំនួយជនរងគ្រោះ :** នាយកដ្ឋានជំនួយជនរងគ្រោះនៃមណ្ឌលសកម្មភាពកំចាត់មីនយេម៉ែន (YEMAC) សម្របសម្រួលជំនួយជនរងគ្រោះ ដោយគ្មានការទាក់ទងជាប្រព័ន្ធជាមួយស្ថាប័នផ្សេងៗឡើយ។
- **ផែនការជួយជនរងគ្រោះៈ** ជំនួយជនរងគ្រោះបានត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពកំចាត់មីន និង ភ្ជាប់ជាមួយកម្មវិធីជំនួយបួនដំណាក់ការផងដែរ។
- **សាវតារជំនួយជនរងគ្រោះ[១០] :** នៅក្នុងឆ្នាំ ២០០៥និង២០០៩ ជំនួយជនរងគ្រោះត្រូវបានអនុវត្តដោយ YEMAC តាមវិធីដូចគ្នាសុទ្ធសាធដែលមានតាំងពីឆ្នាំ២០០១មក។ កម្មវិធីYEMAC មានបួនដំណាក់កាលៈ ចុះពិនិត្យអ្នករស់រានពីមីន និង កាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ធ្វើការពិនិត្យផ្នែកវេជ្ជសាស្ត្រលើតម្រូវការរបស់ពួកគេ ការផ្តល់ការជំនួយស្តារសម្បទា និងវេជ្ជសាស្ត្រ ហើយនិង សមាហរណកម្មសេដ្ឋកិច្ច និង សង្គម។ ផ្នែកសមាហរណកម្ម សេដ្ឋកិច្ច និង សង្គមត្រូវបានផ្ទេរអោយអង្គការក្រៅរដ្ឋាភិបាលចាប់ផ្តើមអនុវត្តនៅក្នុងខែ កញ្ញា ឆ្នាំ ២០០៤ ហើយបានជាប់គាំងតាំងពីឆ្នាំ ២០០៥ មកដោយសារកង្វះមូលនិធិ និង សមត្ថភាព។

ការគាំទ្រផ្លូវចិត្តមិនត្រូវបានផ្តល់ទេដោយសារតែយល់ឃើញថាមិនមែនជាអាទិភាព ហើយក៏គ្មានមូលនិធិសម្រាប់វាដែរ។ ជាសំខាន់ YEMAC បានទទួលខុសត្រូវលើ ថ្លៃព្យាបាល ថ្លៃធ្វើដំណើរ និងកន្លែងស្នាក់នៅរបស់អ្នករស់រានពីមីន និង កាកសំណល់សង្គ្រាម ដែលទទួលសេវាកម្មជាប្រចាំពីបណ្តាញសុខភាពនិងស្តារនីតិសម្បទាឡើងវិញ។ YEMACក៏បានផ្តល់ផងដែរនូវការជំលៀសបន្ទាន់។ គ្រប់សេវាជាមជ្ឈការនៅក្នុងទីក្រុងធំៗ (សាណាអា អាដែន និង តាអីស) ជាកន្លែងដែលអ្នករស់រានស្ទើរតែរស់នៅតំបន់ដាច់ស្រយ៉ាល តំបន់ជនបទដែលតម្រូវអោយពួកគេធ្វើដំណើរយ៉ាងឆ្ងាយ និង ចំណាយពេលច្រើនចេញពីផ្ទះ។ នេះជាបញ្ហាស្មុគស្មាញយ៉ាងខ្លាំងសម្រាប់ស្ត្រី ដែលជាញឹកញាប់ត្រូវការអ្នកថែទាំជាបុរសមកជាមួយ។ ការថែទាំសុខភាពមូលដ្ឋានមិនបង់ប្រាក់ទេ តែការបន្តថែទាំសុខភាពដោយថ្នាំ និង ការប្រើថ្នាំត្រូវបង់ប្រាក់។ មន្ទីរពេទ្យនៅទីក្រុងធំៗ មិនមានបុគ្គលិក និង សម្ភារៈគ្រប់គ្រាន់ទេ តែអាចដំណើរការយន្តការចាំបាច់បាន។ មណ្ឌលស្តារនីតិសម្បទាពឹងអាស្រ័យលើការគាំទ្រពីអន្តរជាតិដែលបន្តធ្លាក់ចុះយ៉ាងខ្លាំងតាំងពីឆ្នាំ ២០០៥ មក ដែលបានជំរុញឱ្យ ICRC ពង្រីកការគាំទ្ររបស់ខ្លួននៅក្នុងឆ្នាំ ២០០៧។ ឱកាសសេដ្ឋកិច្ចសម្រាប់អ្នករស់រាន និងជនពិការមានកំណត់នៅក្នុងកំឡុងពេលកន្លងមកប្រាក់សោធនមិនគ្រប់គ្រាន់ ហើយការរើសអើងមាននៅពាសពេញ។ វិស័យពិការភាព នៅយ៉េម៉ែនមានការអភិវឌ្ឍន៍ និង បានសម្របសម្រួលល្អគ្រាន់បើ តែខ្វះធនធានមនុស្ស និង ហិរញ្ញវត្ថុ។ ជាដដែល សេវាភាគច្រើនមាននៅទីក្រុង រីឯការស្តារនីតិសម្បទាសហគមន៍ (CBR)គឺ "មិនមានសោះឡើយ " ជាលទ្ធផលមានតែជនពិការ ១.៥% មានលទ្ធភាពទទួលសេវា ហើយស្ត្រីពិការទទួលសេវាកាន់តែតិចទៅទៀត[១១]។ អ្នករស់រានពីមីន/កាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមស្ទើរតែមិនដែលបានបញ្ចូលទៅក្នុង ឬ ធ្វើអោយយល់ដឹងទូលំទូលាយពីកម្មវិធីពិការភាព។ មានសេចក្តីរាយការណ៍ថាបានឃើញអ្នករស់រានកំពុងទទួលការជួយជ្រោមជ្រែងនៅកន្លែងផ្សេង "ជាករណីពិសេស "[១២]។

**ការទទួលជំនួយពីក្រុមអ្នកផ្តល់ជំនួយផ្សេងៗ**




## ភាពជឿនលឿនពីជំនួយជនរងគ្រោះនៅមូលដ្ឋាន

### *សាវតារអ្នកផ្តល់ចម្លើយ*

នៅប្រទេសយ៉េម៉ែន នៅខែ កក្កដា ឆ្នាំ ២០០៩ ចម្លើយតបនឹងកម្រងសំណួរបានពីអ្នករស់រាន ៥៥ នាក់ ស្តីអំពីភាពជឿនលឿនលើជំនួយជនរងគ្រោះតាំងពីឆ្នាំ ២០០៥ ត្រូវបានប្រើ លើបុរស ៣២ នាក់ ស្ត្រី ១៨ នាក់ កុមារី២ នាក់ និង កុមារា ៣ នាក់។ អ្នកផ្តល់ចម្លើយមានអាយុរវាង ១៤ ឆ្នាំ និង ៨០ ឆ្នាំ ហើយ៥៥% មានអាយុរវាង ២១ ឆ្នាំ និង ៤០ ឆ្នាំ។ ហើយមនុស្ស

៣០ នាក់ (៥៥%) ជាមេគ្រួសារ ហើយ ១៨% នៃអ្នកឆ្លើយជាម្ចាស់ព្រទ្យ។ អ្នកឆ្លើយមកពីតំបន់ប៉ះពាល់ ដោយសារមីននៅក្នុង អាលដាឡេ អីប អាវ៉ាន់ ឡាបេ និង អាល់បាយដា ហើយ ក៏មកពី អាដែនតាអិស និង សានាអាផងដែរ។ ប្រជាជនភាគច្រើន រស់នៅក្នុងភូមិដែលសេវាមានកំរិត (៣០/៥៥%) ហើយប្រាំនាក់រស់នៅតំបន់ដាច់ស្រយាលដោយគ្មានសេវា ហើយ ១៩ បានរស់ នៅទីក្រុងធំឬរដ្ឋធានី។ ហើយស្ត្រីម្នាក់មិនមានទីលំនៅពិតប្រាកដ ហើយត្រូវផ្លាស់ទីតាំងការរស់នៅរវាងសមាជិកគ្រួសារនានា។

អ្នកឆ្លើយតែ ១១%ប៉ុណ្ណោះ បាននិយាយថា ប្រាក់ចំណូលរបស់គេគ្រប់គ្រាន់ ហើយ ៧៨%បាននិយាយថា មិនគ្រប់គ្រាន់ ហើយអ្នកនៅសល់មិនបានឆ្លើយទេ។ មនុស្សម្នាក់មិនមានការងារធ្វើនៅមុនពេលឧប្បត្តិហេតុកើតឡើង ហើយ ១៥ នាក់នៅ សិក្សានៅពេលនោះ (រួមទាំងបីនាក់ដែលនៅកុមារនៅពេលស្រាវជ្រាវនោះ)។ ក្រោយឧប្បត្តិហេតុប្រាំនាក់បាននិយាយថា អត់ ការងារធ្វើ ហើយ ២៣ មិនបានផ្តលលចម្លើយទេ[១៣]។ អ្នកឆ្លើយសំណួរទាំងអស់បាននិយាយថា ដោយសារពិការភាព បានធ្វើ អោយគេបាត់បង់ ឬ ផ្លាស់ប្តូរការងារ។ ស្ទើរតែពាក់កណ្តាលនៃអ្នកឆ្លើយ (៤៥%) ជាអនក្ខរជន ហើយមានតែ ៣៣% បានឆ្លង ផុតការអប់រំបឋមសិក្សា។ ប្រជាជនភាគច្រើនបានជួបឧប្បត្តិ ហេតុនៅពេលក្មេង។ សាវតារអ្នកឆ្លើយទាក់ទងទៅនឹងសាវតារជន រងគ្រោះនៅក្នុងយេម៉ែន ដែលឧប្បត្តិហេតុភាគច្រើនកើតឡើងនៅក្នុងតំបន់ជនបទ ហើយជារឿយៗចំពោះប្រជាជនក្មេងៗ។ ស្ត្រី និង កុមារបានបង្កើតនូវសមភាពដ៏សំខាន់នៃជនរងគ្រោះដែលជាទម្លាប់គេមើលសត្វពាហនៈ ឬរកអុស ឬ ម្ហូបអាហារ ហើយ ជាពិសេសក្មេងស្រីបានប្រឈមនឹងហានីភ័យ។

***ការរកឃើញទូទៅ***

ជារួម ភាគច្រើននៃអ្នកឆ្លើយមានអារម្មណ៍ថា សេវានានានៅដដែលហើយមានកំរិតតាំងពីឆ្នាំ ២០០៥ មកម្លេះ ជាពិសេស នៅក្នុងផ្នែកនៃការស្តារនីតិសម្បទា និងការស្តារសេដ្ឋកិច្ចឡើងវិញ។ អ្នកឆ្លើយ បីភាគបួន (៧៧%) មិនមានអារម្មណ៍ថា គេបាន ទទួលសេវាច្រើនទេ ហើយ ៧៣%ទៀតមិនបានគិតថា សេវាឥឡូវប្រសើរជាងមុន នោះទេបើប្រៀបធៀបទៅនឹងឆ្នាំ ២០០៥។ ប្រជាជនរស់នៅទីក្រុងធំៗបានកត់សំគាល់ឃើញថា មានការល្អប្រសើរឡើង (៣២%បើប្រៀបធៀបទៅនឹង ២២%នៅកន្លែង ផ្សេងៗ)។ ហើយ ១៦% បានគិតថា សេវាសម្រាប់ស្ត្រី" អវត្តមាន "បើប្រៀបធៀបទៅនឹងបុរស ហើយ ២០% បានគិតថាសេវា របស់ស្ត្រី" យ៉ាប់" ហើយ ៣១% បានគិតថាសេវាសម្រាប់ស្ត្រីដូចគ្នាទៅនឹងបុរសដែរ ហើយ ៣១% ទៀតបានគិតថា សេវារបស់ស្ត្រី គ្រាន់បើជាងបុរស[១៤]។ ស្ត្រី និង ក្មេងស្រីឆ្លើយវិជ្ជមានជាងបុរស។ ៣៥% នៃស្ត្រី និង ៣៥% នៃក្មេងស្រី បាននិយាយថា សេវា របស់ស្ត្រី" ស្មើគ្នា ឬ គ្រាន់បើជាង" ។ ហើយ ៥៨%បាននិយាយថា សេវាសម្រាប់កុមារ" មិនដែល" ឬ "ស្ទើរតែមិនដែល" អនុលោម ទៅតាមអាយុ ការរកឃើញគួរតែជាការពិតដោយសារអ្នកឆ្លើយភាគច្រើននៅក្មេងនៅពេលគេជួបឧប្បត្តិហេតុ។

អ្នកឆ្លើយជាង ៣១% មិនដែលបានត្រូវស្ទង់មតិដោយអង្គការក្រៅរដ្ឋាភិបាល ឬ រដ្ឋាភិបាលតាំងពីឆ្នាំ ២០០៥មក ម្លេះ។ ១៥% ត្រូវបានស្ទង់មតិបីដងឬ ច្រើនជាងនេះ។ ហើយ ៦៥% បាននិយាយថា ដោយសារអញ្ចឹង គេបានទទួលព័ត៌មានច្រើនអំពី សេវា។ ៣៨%បាននិយាយផងដែរថា គេបានទទួលសេវាច្រើនជាងមុន។ ២៧% បានរាយការណ៍ថាមានការលំបាកតិចតួចក្នុង ការទទួលសោធននិវត្សន៍ ឬ មានអារម្មណ៍ចង់ស្តាប់។ ហើយអ្នករស់រាន ៣៦% បានមានឱកាស ដើម្បីពន្យល់ពីសេចក្តីត្រូវការ របស់គេដល់តំណាងរដ្ឋាភិបាល។ លទ្ធផលទាំងនេះនាំអោយឈានដល់ការបង្កើតកម្មវិធីជំនួយជនរងគ្រោះ YEMAC ដូចដែល កំណត់ហេតុអ្នករស់រានត្រូវបានសំភាសន៍ជាប្រព័ន្ធដើម្បីកំណត់ថាតើគេត្រូវការសេវាឬទេ។ យោងតាមឯកសារ YEMAC ២០៣៣ ករណី បានត្រូវបើកធ្វើនាខែមិនា ឆ្នាំ ២០០០ ហើយ ៨១% នៃសុំណុំរឿងទាំងនេះ បានទទួលសេវា (មានជាង ២៥០០ ករណី ត្រូវ បានកត់ត្រាថា ជាអ្នករស់រាននៅយេម៉ែន)[១៥]។ ទោះយ៉ាងណា លទ្ធផលទាំងនេះ ឆ្លើយតបទៅនឹងរបាយការណ៍របស់រដ្ឋាភិបាល

និង អ្នករស់រានដែលថា មិនមែនទាំងអស់នៃអ្នកទាំងនោះ ត្រូវបាននៅក្នុងការស្រាវជ្រាវស្ដីពីផលប៉ះពាល់នៅក្នុងឆ្នាំ ២០០០ ត្រូវបានចុះពិនិត្យឬជួយទេ ហើយថាការប្រឈមគឺទទួលការតាមដានលើការថែទាំក្រោយពីព្យាបាលលើកទីមួយរួច[១៦] ។ ប្រហែលជាមានន័យថា អ្នកឆ្លើយតបទាំងអស់ត្រូវបានចុះពិនិត្យមុនឆ្នាំ ២០០៥ តែមិនមែនក្រោយទេ។

**និន្នាការរួមនៃសេវាសម្រាប់អ្នករស់រានចាប់តាំងពីឆ្នាំ ២០០៥**




## ***សង្គ្រោះបន្ទាន់និងការថែទាំបន្តផ្នែកវេជ្ជសាស្ត្រ***

ជិតពាក់កណ្ដាលនៃអ្នកឆ្លើយទាំងអស់(៤៥%) មានអារម្មណ៍ថា ការថែទាំសុខភាពនៅដដែលទេ ចាប់តាំងពីឆ្នាំ ២០០៥មកហើយ ២៧% បានឃើញនូវភាពជឿនលឿនហើយ ២២%បានឃើញថាយ៉ាប់ឡើង[១៧] ។ អ្នកនៅទីក្រុងភាគច្រើនបំផុតមើលឃើញភាពជឿនលឿនទៅមុខគ្មាននរណាម្នាក់មកពីជនបទទេ។ អ្នកឆ្លើយជាងពាក់កណ្ដាល (៥៥%)បានគិតថាអ្នករស់រាន "មិនដែល" ឬ" ស្ទើរតែមិនដែល " បានទទួលសេវាថែទាំសុខភាពតាមតម្រូវការរបស់គេ ហើយ ២៩% បានឃើញថា" ជួនកាល" វាជាករណី ។ ជិត ១ភាគ៣ បានគិតថានិតិវិធីវេជ្ជសាស្ត្រស្មុគស្មាញអាចត្រូវអនុវត្តច្រើនជាងមុន។ ហើយភាពជឿនលឿនទៅមុខនៃសូចនាករអ្នកឆ្លើយ១៥% បានឃើញភាពប្រសើរឡើងនៅក្នុងវិស័យអោយថ្នាំត្រូវច្រើនសម្ភារៈបរិក្ខាច្រើន បុគ្គលិកហ្វឹកហ្វឺនបានប្រសើរលទ្ធភាពរូបវន្តល្អច្រើន មានការដឹកជញ្ជូនគ្រាមានអាសន្នច្រើន ហើយអ្នកជួយបឋមឬកាន់តែងាយស្រួលបញ្ជូន។ (៤%) បានកត់សំគាល់ភាពជឿនលឿន តិចតួចនៅក្នុងការទទួលបានការថែទាំសុខភាពកាន់តែក្បែរផ្ទះខណៈដែល៥% បានគិតថា រដ្ឋាភិបាលគាំទ្រអោយបង្កើនការថែទាំសុខភាព។ អ្នកអនុវត្តពាក់កណ្ដាលក៏បានគិតថា ការថែទាំដោយថ្នាំនៅតែដដែល ហើយគ្មាននរណាបានគិតថា មានមណ្ឌលច្រើននៅតំបន់ប៉ះពាល់ដោយសារមីន។ ហើយល្អបំផុតប្រតិបត្តិករបានគិតថា រដ្ឋាភិបាលបានរក្សាកិច្ចប្រឹងប្រែងរបស់ខ្លួន។

លទ្ធផលទាំងនេះឆ្លើយតបទៅនឹងស្ថានភាពនៅយេម៉ែន ជាកន្លែងដែលការថែទាំសុខភាពនៅក្នុងតំបន់ជនបទកម្រនឹងមានហើយពិបាកនឹងទៅដល់ជាពិសេសសំរាប់ជនពិការ។ នីតិវិធីស្មុគស្មាញត្រូវបានគេអនុវត្តនៅក្នុងទីក្រុងធំ៧(ភាគច្រើននៅសាណាអាអាដែននិងតាអិស)ហើយមិនបង់ប្រាក់ទេ។ ជាទូទៅកង្វះធនធានមនុស្ស ការឱ្យថ្នាំនិងបរិក្ខាមិនគ្រប់គ្រាន់ ត្រូវបានរាយការណ៍នៅក្នុងកំឡុងនោះ[១៨] ។ អ្នកផ្ដល់សេវាតែមួយគត់សម្រាប់អ្នករស់រានពីមីន/កាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមគឺកម្មវិធីជំនួយជនរងគ្រោះ YEMAC ដែលត្រូវប្រមូលផ្ដុំមនុស្សជុំគ្នាសម្រាប់ធ្វើដំណើរទៅទីក្រុងធំមួយដោយផ្ដល់ម្ហូបអាហារ និងកន្លែងស្នាក់នៅ

និងបង់ថ្លៃព្យាបាលផងដែរ។ លទ្ធផលទាំងនេះត្រូវបាន បញ្ជាក់អះអាងនៅក្នុងការវាយតម្លៃពីការរកឃើញផងដែរ នៅក្នុងមជ្ឈមណ្ឌលដោះមីន មនុស្សធមិអន្តរជាតិនៅទីក្រុងហ្សឺណែវថា "អ្នករស់រានភាគច្រើនបំផុត " មិនបានដឹងពីកម្មវិធីជំនួយជនរងគ្រោះពីមីន/យុទ្ធភណ្ឌមិនទាន់ផ្ទុះ ហើយគេព្យាយាមធ្វើឱ្យល្អបំផុតតាមដែលអាចធ្វើទៅបានដោយគ្មានការគាំទ្រថ្នាំគ្រប់គ្រាន់ "ក៏ដោយ[១៩]។ ជាគោល ការណ៍ការថែទាំមូលដ្ឋាននិងសង្គ្រោះបន្ទាន់គឺមិនបង់ប្រាក់ តែអ្នករស់រានរាយការណ៍ថាបង់ថ្លៃ។ YEMAC បានព្យាយាមផ្តល់ការជម្លៀសបន្ទាន់ តែអ្នករស់រានភាគច្រើនបំផុតមិនបានឃើញភាពជឿនលឿនទៅមុខនៅក្នុវិស័យនេះទេ ដោយសារបញ្ហាសណ្ឋានដី និងកង្វះភាពកែលំអទូទៅដោយរដ្ឋាភិបាលឬក៏ដោយសារតែពួកគេមិនត្រូវការប្រភេទជំនួយនេះទេ។ ការវាយតម្លៃរបស់ក្រសួងសុខភាពសាធារណៈនិងប្រជាជន (MoHP) អំពីហេដ្ឋារចនាសម្ព័ន្ធសុខភាព និងការកែលំអជាបន្តបន្ទាប់សម្រាប់ឆ្នាំ ២០០៦ នៅមិនទាន់បានធ្វើនៅឡើយទេ។

***ការស្តារនីតិសម្បទា***

អ្នកឆ្លើយភាគច្រើនលើសលុប(៧១%)បាននិយាយថា ការស្តារនីតិសម្បទាចាប់តាំងពីឆ្នាំ២០០៥មកនៅដដែល ហើយ ១៥% បានរាយការណ៍ថាមានការកែលំអ និង ១៣% ថា ចុះអន់ថយ ហើយម្នាក់ទៀតមិនឆ្លើយ។ ទោះយ៉ាងណា ៥៨%បាននិយាយថា អ្នករស់រាន" មិនដែល" បានទទួលការស្តារនីតិសម្បទាដែលគេត្រូវការទេ ហើយ ២២% បានឃើញថានេះ " ស្ទើរតែមិនមែន" ជាករណីទេ។ អ្នករស់រានច្រើនលើសលុបបានយល់ឃើញថា មិនមានភាពជឿនលឿននៅក្នុងសូចនាករជាក់លាក់ស្តីពីភាពជឿនលឿនណាមួយនោះ។ ផ្នែកដែលបានឃើញមានការជឿនលឿនទៅមុខខ្លាំង(សូម្បីតែអ្នកឆ្លើយ១៣%)គឺគុណភាពឧបករណ៍ចល័ត។ ហើយតិចជាង១៣% មើលឃើញភាពជឿនលឿនគ្រប់សូចនាករទាំងអស់ ដូចជាបុគ្គលិកបានទទួលការហ្វឹកហ្វឺនល្អ បរិក្ខារល្អប្រសើរ ការព្យាបាលដោយចលនាប្រសើរឡើង និង មិនរងចាំយូរ។ ហើយជំរើសលទ្ធភាពទទួលបានសេវាកាន់តែជិតផ្ទះ និងមានកន្លែងធ្វើដៃជើងចល័តមាន៥%ឬតិចជាងនេះបើនិយាយអំពីភាពជឿនលឿន។ អ្នកអនុវត្ត៧៥%បានគិតថាការស្តារនីតិសម្បទានៅតែដដែល។ ជារួមភាគច្រើនបានគិតថា រដ្ឋាភិបាលបានកាត់បន្ថយកិច្ចប្រឹងប្រែងរបស់ខ្លួន ជាពិសេសក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ការតាមដាន និង ការដាក់ឧបករណ៍ជំនួស។

នេះអាចត្រូវបានពន្យល់ដោយការពិតថាកម្មវិធី YEMAC មិនមានការផ្លាស់ប្តូរជាសំខាន់អ្វីទេតាំងពីឆ្នាំ២០០១ មក។ ដូចនេះអ្នកទទួលសេវាពី YEMAC នៅតែទទួលសេវាដូចមុនដដែល។ ការស្តារនីតិសម្បទាមាននៅតែទីក្រុងធំៗ និង នៅក្នុងតំបន់ដាច់ស្រយ៉ាលដែលរងផលប៉ះពាល់ដោយមីន ( អាល់មូកាលា នៅក្នុងការគ្រប់គ្រងហាដ្រាមាក) ដែលវាពិបាកនឹងទៅដល់មណ្ឌលនោះ។ នៅឆ្នាំ២០០៥ យេម៉ែនបានធ្វើការប៉ាន់ប្រមាណថា មិនចាំបាច់មានអ្នកធ្វើការសម្រាប់សហគមន៍ស្តារនីតិសម្បទាទេ អញ្ចឹងហើយបានជាគ្មានកិច្ចប្រឹងប្រែងដើម្បីនាំយកសេវាទៅកៀកនឹងប្រជាជន[២០]។ អវត្តមាននូវចម្លើយតបវិជ្ជមានចំពោះភាពជឿនលឿននៃសុចនាករអាចត្រូវបានពន្យល់ថា ដោយសារការប្រឈមខាងវិស័យស្តារនីតិសម្បទាចាប់តាំងពីឆ្នាំ ២០០៤មកម្ល៉េះ។ វាជាផ្នែកមួយដោយសារការទទួលខុសត្រូវរបស់រដ្ឋាភិបាលមិនច្បាស់លើការស្តារនីតិសម្បទា ហើយក្រសួងសុខភាពសាធារណ និង ប្រជាជន និង ក្រសួងសង្គមកិច្ចការងារផ្តល់ការគាំទ្រហិរញ្ញវត្ថុដល់វិស័យនេះ។ ទោះយ៉ាងណា ក្រសួងនីមួយៗផ្តល់ការគាំទ្រមិនគ្រប់គ្រាន់ ហើយមិនអាចទទួលបានមូលនិធិក្នុងពេលដូចគ្នាពីក្រសួងទាំងពីរទេ។ ការប្រឈមក៏ដោយសារបណ្តាលមកពីការចាកចេញរបស់អង្គការអន្តរជាតិដែលបានគាំទ្រវិស័យនេះនៅក្នុងឆ្នាំ២០០៥-២០០៦។ វាបណ្តាលអោយខ្វះមូលនិធិ បាត់បង់បុគ្គលិក ខ្វះសម្ភារៈនៅមណ្ឌលអាដែន និង តាអីស ហើយនឹងដំណើរការមិនប្រក្រតីរបស់អង្គភាពព្យាបាល ដោយចលនានៅអាដែន ដោយសារបុគ្គលិកខ្វះសមត្ថភាព។ ការទទួលខុសត្រូវរបស់ក្រសួងទាំងពីរក្នុងការទទួលយកមណ្ឌលអាដែនធ្លាក់ចុះ

បណ្តាលឱ្យ ICRC ពង្រីកប្រតិបត្តិការរបស់ខ្លួនដើម្បីគ្របដណ្តប់លើមណ្ឌលនេះតាំងពី ពាក់កណ្តាលឆ្នាំ ២០០៧ មក។ សរុបមកវិញ ពេលវេលាកំណត់ធ្វើការប៉ាន់ប្រមាណរបស់ MoHP នៅក្នុងឆ្នាំ ២០០៦ មិនបានធ្វើរហូតមក។

### ការគាំទ្រផ្លូវចិត្ត និង សមាហរណកម្មសង្គម

អ្នកឆ្លើយជិតពាក់កណ្តាល (៤៩%) បាននិយាយថា សេវាគាំពារផ្លូវចិត្ត និង សង្គម មិនមានការផ្លាស់ប្តូរអ្វីទេតាំងពីឆ្នាំ ២០០៥មក ហើយ២០% បានឃើកថា ប្រសើរឡើង ហើយ ២០% ទៀត បានឃើញថា យ៉ាប់ជាងមុន[២១]។ ១១% បាននិយាយថាអ្នករស់រាន "ភាគច្រើនបំផុត" ឬ "តែងតែ" បានទទួលសេវាគាំទ្រផ្លូវចិត្តដែលគេត្រូវការ។ ទោះជាយ៉ាងណាបើប្រៀបធៀបទៅនឹងជំនួយក្នុងការស្តារនីតិសម្បទានិងការផ្តល់ថ្នាំនោះ មានមនុស្សជាច្រើន បានមើលឃើញថាប្រសើរឡើងតាមករណីនៃប្រភេទការគាំទ្រនេះ។ ហើយចំនួន ៣៥%បានគិតថា ឥឡូវនេះសេវាគាំទ្រផ្លូវចិត្តមានសារៈសំខាន់ស្មើនឹងសេវាឯទៀតៗ ហើយ ២៥% បានជឿថាអ្នករស់រានតែងត្រូវបានចាត់ថាជា "ករណីសប្បុរសធម៌មិនទៀតហើយ" ហើយ ១៥%ទៀត បានចូលរួមនៅក្នុងសកម្មភាពផ្តល់សេវាផ្លូវចិត្ត។ ៣ភាគ៤នៃអ្នកប្រតិបត្តិបានយល់ថា សេវាផ្លូវចិត្ត យ៉ាប់ជាងមុន ហើយគេតែងគិតថារដ្ឋាភិបាល "មិនបានធ្វើអ្វីសោះ" ដើម្បីធ្វើអោយសេវាប្រសើរឡើង។

**ការបំពេញតម្រូវការរបស់អ្នករស់រានចាប់តាំងពីឆ្នាំ ២០០៥ មក**




ចម្លើយអ្នករស់រានលុបបានមិនមានវិជ្ជមានខ្លាំងទេ។ ពួកគេមានចម្ងល់យ៉ាងខ្លាំងដោយសារកង្វះការគាំទ្រទាំងស្រុងពីរដ្ឋាភិបាលដល់អ្នករស់រានក្នុងផ្នែកនេះ។ បើទោះជាមានមណ្ឌលផ្តល់សុខភាពខ្លះនៅអាដែន និង សាណាអា ក៏ដោយក៏គ្មានអ្នករស់រានណាម្នាក់ត្រូវបានជួយតាមរយៈនោះដែរ។ នៅចន្លោះឆ្នាំ ២០០៥ និង ២០០៩ YEMAC មិនបានធ្វើសកម្មភាពគាំទ្រផ្លូវចិត្តទេដោយសារកង្វះមូលនិធិ។ YEMAC បានធ្វើការកត់សំគាល់បន្ថែមថា ពេញកំឡុង ២០០៥-២០០៩ ការគាំទ្រផ្លូវចិត្តមិនមែនជាអាទិភាពទេ ព្រោះអ្នករស់រានបានទទួលការគាំទ្រនេះនៅក្នុងបណ្តាញគ្រួសារហើយ[២២]។ ការវាយតម្លៃ GICHD ឆ្នាំ២០០៦ "បានសង្កត់បញ្ជាក់ថា តម្រូវសេវាថែទាំសុខភាពផ្លូវចិត្ត ជួនកាលវាសំខាន់ដូចតម្រូវការសុខភាពផ្លូវកាយអញ្ចឹង " ហើយចាំបាច់ត្រូវរួមបញ្ចូលទៅក្នុងសេវានានា[២៣]។ ហេតុដូចនេះ ចម្លើយតបវិជ្ជមាននៅក្នុងផ្នែកនេះទំនងជាទាក់ទងទៅនឹងការពិតដែលថា អង្គការជាតិទាំងពីរដែលបានធ្វើការស្រាវជ្រាវក៏បានធ្វើការនៅក្នុងឃុំទាំងនេះផងដែរ ហើយអ្នកឆ្លើយខ្លះក៏ជាសមាជិកឬអ្នកទទួលផល

នៃអង្គការទាំងនេះ។ បណ្តាញCBRក៏មានតែវាមិនបានធ្វើការជាក់លាក់ជាមួយអ្នករស់រានពីមីន/កាកសំណល់ពីសង្គ្រាមទេ តែជាសំខាន់ជាមួយអ្នកស្ម័គ្រចិត្ត ដោយសារមានអាទិភាពប្រកួតប្រជែងគ្នាជាច្រើន ហើយនឹងកំណើននៃតម្រូវការ។

***សមាហរណកម្មសេដ្ឋកិច្ច***

ក្នុងចំណោមអ្នកឆ្លើយតប២៩% បានជឿជាក់ថា ឱកាសសមាហរណកម្មសេដ្ឋកិច្ចយ៉ាប់យឺនឡើងតាំងពីឆ្នាំ២០០៥មកម្ល៉េះ ហើយ ៣៨% បានគិតថាស្ថានភាពនៅដដែលមិនផ្លាស់ប្តូរទេ។ មនុស្សចំនួន ៤២% បានឃើញថា អ្នករស់រាន " មិនដែល "ទទួលជំនួយសមាហរណកម្មសេដ្ឋកិច្ចដែលគេត្រូវការនោះទេ រីឯ ១៥% ថាជាករណើរ" ស្ទើរតែមិនដែល "បាន ហើយ ៦% បាននិយាយថា អ្នករស់រាន " ភាគច្រើនបំផុត " ឬ "តែងតែ "ទទួលបានតាមតម្រូវការ។ ហើយអ្នករស់រានស្ទើតែទាំងអស់ (៩៥%) បានគិតថា គេជាជំរើសចុងក្រោយដែលត្រូវជ្រើសរើសអោយធ្វើការងារ។ រីឯ១០%បានគិតថា សមាហរណកម្មសេដ្ឋកិច្ចរបស់អ្នករស់រានជាអាទិភាពរបស់រដ្ឋាភិបាល។ ១ភាគ៥ បាននិយាយថា ប្រព័ន្ធកូតាការងារអនុវត្តបានល្អ។ អ្នកឆ្លើយតិចជាង ១៥%បានមើលឃើញភាពជឿនលឿនទៅមុខនៅក្នុងសូចនាករ ដូចជា ការរើសអើងធ្លាក់ចុះ ប្រាក់សោធនប្រសើរឡើង ទទួលបានការហ្វឹកហ្វឺនវិជ្ជាជីវៈល្អប្រសើរ ស្របតាមតម្រូវការទីផ្សារ ការអប់រំ និង ឱកាសការងារច្រើន ការយល់ដឹងកើនឡើង ឬ គ្រូបង្រៀនល្អ។ អ្នកប្រតិបត្តិជិតពាក់កណ្តាលបានគិតថា ឱកាសធ្វើសមាហរណកម្មសេដ្ឋកិច្ចមានធ្លាក់យ៉ាប់យឺនតាំងពីឆ្នាំ២០០៥មកម្ល៉េះ។

ចម្លើយ ជាមួយនឹងការប្រឈមទាំងនេះ YEMAC បានប្រឈមនៅក្នុងការបង្កើតសមាហរណកម្មសេដ្ឋកិច្ចជោគជ័យ។ នៅក្នុងឆ្នាំ ២០០៤ YEMAC បានគាំទ្រការបង្កើតអង្គការ (សមាគមន៍យេម៉ែន សម្រាប់អ្នករស់រានពីមិន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ (YALS) ដើម្បីគោលបំណងនេះ តែអង្គការនេះបានប្រឈមនឹងឧបសគ្គហិរញ្ញវត្ថុ និង សមត្ថភាពចាប់តាំងពីមូលនិធិជប៉ុនបានចប់នៅក្នុងឆ្នាំ២០០៥មក។ មានចំនួនមនុស្សតិចឡើងបានទទួលការហ្វឹកហ្វឺន តែចំនួនតិចឆ្ងាយជាង ចំនួន ៥០០នាក់ដែល YEMACបានប៉ុនប៉ងផ្តល់ឱកាសហ្វឹកហ្វឺននៅក្នុងឆ្នាំ២០០៥-២០០៩[២៤] ។ អង្គការមួយចំនួនទៀតបានធ្វើការលើផ្នែកហ្វឹកហ្វឺនវិជ្ជាជីវៈ និង សមាហរណកម្មសេដ្ឋកិច្ចដល់ជនពិការ ហើយយូរៗក៏មានបញ្ចូលអ្នករស់រានផងដែរ ហើយ YEMAC មិនទំនងជាបញ្ជូនមនុស្សទៅមណ្ឌលទាំងនោះទេ (ជាឧទាហរណ៍ នៅអាដែន ជាកន្លែងដែលបញ្ជូនមនុស្សទៅទទួលការស្តារនីតិសម្បទា តែមិនមែនសម្រាប់សមារណកម្មសេដ្ឋកិច្ចទេ។ ក៏មានការផ្តួចផ្តើមផ្សេងៗទៀតដែរតាមរយៈមូលនិធិសង្គមដើម្បីអភិវឌ្ឍន៍ ( SFD ) ស្ថាប័នមានស្វ័យភាពពាក់កណ្តាលដែលមានកម្មវិធីផ្សេងៗជាច្រើនសម្រាប់ជនងាយរងគ្រោះ តែចំនួនអ្នករស់រានដែលទៅទទួលសេវា នៅក្នុងតំបន់ប៉ះពាល់ទាំងនោះហាក់មានកំរិត។ កំណើនអត់ការងារមានតាំងពី ឆ្នាំ (២០០៤)មក ហើយកង្វះឱកាសនៅក្នុងតំបន់ជនបទរឹតតែបង្កើនឧបសគ្គដល់អ្នករស់រាន និង ជនពិការថែមទៀត។ តាមការប៉ាន់ប្រមាណមានតែជនពិការ ១២%បានទទួលការងារធ្វើ ហើយ0.0៧%បានទទួលការគាំទ្រពីរដ្ឋាភិបាលដើម្បីទទួលបានការអប់រំ[២៥] ។ ប្រាក់សោធនមិនគ្រប់គ្រាន់ ហើយជនពិការតែ១០%ប៉ុណ្ណោះបានទទួល។ អ្នករស់រានភាគច្រើនបំផុតមានភាពវិជ្ជមាននៅក្នុងការស្រាវជ្រាវដោយបានទទួលការគាំទ្រតាមរយៈអង្គការក្រៅរដ្ឋាភិបាលដែល YEMAC បានប្រគល់អោយនូវការងារសមាហរណកម្មសេដ្ឋកិច្ចឡើងវិញ។

***ច្បាប់ និង គោលនយោបាយសាធារណៈ***

អ្នកឆ្លើយ ៣៥%បានគិតថាសិទ្ធិរបស់ពួកគេ បានត្រូវគោរពបើប្រៀបធៀបទៅនឹងឆ្នាំ ២០០៥ រីឯ ៤២% បាននិយាយថា ស្ថានភាពនៅដូចដើម។ ទោះយ៉ាងណា ៧១% បានគិតថា សិទ្ធិអ្នករស់រាន "មិនដែល" ឬ "ស្ទើរតែ មិនដែល "ត្រូវបានបំពេញតាមសិទ្ធិរបស់គេទេ។ នៅពេលក្រឡេកមើលផ្នែកជឿនលឿនជាក់លាក់ ៣៨% បានគិតថា ការយល់ដឹងពីសិទ្ធិរបស់អ្នករស់រានបានកើនឡើង ៣៣% បានគិតថា ការរើសអើងបានថយចុះ ហើយ ២៥% បាននិយាយថា គេបានទទួលព័ត៌មានច្រើនអំពីសិទ្ធិ។ ផ្នែក

ដែលមានភាពជឿនលឿនតិច គឺការអនុវត្តន៍ច្បាប់ (១៥%បានឃើញភាពប្រសើរឡើង) និងវត្តមានរបស់រដ្ឋាភិបាល (៧%បានឃើញភាពប្រសើរឡើង)។ អ្នកអនុវត្តមានលក្ខណៈវិជ្ជមានច្រើន ដោយ៧៥% បានឃើញមានភាពជឿនលើនទៅមុខ។ គេបានកត់សំគាល់ភាពប្រសើរឡើងនៅក្នុងការអភិវឌ្ឍន៍គោលនយោបាយថ្មីៗ និង ការធ្លាក់ចុះនៃការរើសអើង។ ភាពជឿនលឿនតិចបំផុតត្រូវបានមើល ឃើញនៅក្នុងការអនុវត្តន៍ច្បាប់។

ចម្លើយហាក់ដូចជាវិជ្ជមានដែលមិនទាក់ទងទៅនឹងសកម្មភាពរបស់ YEMAC ដោយវាមិនដែលបានផ្តោតទៅ លើបញ្ហាសិទ្ធិ ឬ បង្កើនការយល់ដឹងទេ។ កិច្ចខិតខំប្រឹងប្រែងទាំងនោះឋិតនៅលើអង្គការ ដែលបានសកម្មលើបញ្ហា និង បានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់គេតាំងតែពីយ៉េម៉ែនបានចុះហត្ថលេខាលើ UNCRPD ជាពិសេសអង្គការសង្គ្រោះ កុមារ។ SFD បានធ្វើយុទ្ធនាការបង្កើនការយល់ដឹង ហើយគំរោងពិការភាពដ៏ធំត្រូវបានចាប់ផ្តើមឡើងដោយធនាគា ពិភពលោក ដោយមានបំណងជួយរដ្ឋាភិបាលក្នុងការបង្កើតយុទ្ធសាស្ត្រពិការភាព។ សកម្មភាពមានកំរិតរបស់ YALS ក៏បានដៅលើការបញ្ចុះបញ្ចូល និង បង្កើនការយល់ដឹងសិទ្ធិអ្នករស់រាន។

នៅពេលបានសួរថា តើគេនឹងឆ្លើយតបយ៉ាងណាប្រសិនបើអ្នករស់រាននៅយ៉េម៉ែននិយាយថាស្ថានភាពរបស់គេ ក្នុងពេលប្រាំឆ្នាំកន្លងមកនេះនៅដដែលនោះ YEMAC បាននិយាយថានេះជា" កិត្តយសរបស់ YEMAC ណាស់ ដោយខ្លួនបានគ្រប់គ្រងដើម្បីរក្សាស្ថានភាពអោយនៅថេរនៅពេលគ្មានលុយ និង គ្មានសមត្ថភាពនោះ។

## ការសម្រេចបានលើដំណើរការជួយជនរងគ្រោះ

| ឆ្នាំ | ទម្រង់ J និយាយពីការជួយដល់ជនរងគ្រោះ | សេចក្តីថ្លែងការណ៍នៅ ឯកិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍ស្តីពីការជួយជនរងគ្រោះ | សេចក្តីថ្លែងការណ៍នៅឯកិច្ចប្រជុំរដ្ឋភាគីស្តីពីការជួយជនរងគ្រោះ | អ្នកជំនាញផ្នែកជំនួយជនរងគ្រោះ | អ្នករស់រានជីវិតពីមីនជាគណៈប្រតិភូ |
|---|---|---|---|---|---|
| ២០០៥ | មាន | មាន | មាន | គ្មាន | គ្មាន |
| ២០០៦ | មាន | មាន | មាន | គ្មាន | គ្មាន |
| ២០០៧ | មាន | មាន | មាន | មាន | គ្មាន |
| ២០០៨ | មាន | គ្មាន | មាន | មាន | គ្មាន |
| ២០០៩ | មាន | មាន | មិនដឹង | គ្មាន | គ្មាន |

ចំណាំ: តាមពិតយេម៉ែន បានផ្តល់ព័ត៌មានពីជំនួយជនរងគ្រោះនៅក្នុងទម្រង់ ១របស់ខ្លួននៃមាត្រា៧ របាយការណ៍ស្តីពីតម្លាភាព មិនមែននៅ ក្នុងទម្រង់ចេទេ

នៅចន្លោះឆ្នាំ២០០៥-២០០៩ យ៉េម៉ែនបានបន្តកម្មវិធីជំនួយជនរងគ្រោះដែលបានដំណើរការតាំងពីឆ្នាំ ២០០១ មកនោះ។ កម្មវិធីជំនួយជនរងគ្រោះ ត្រូវបានដំណើរការដាច់តែឯងដោយមន្ទីរកម្មវិធីជំនួយជនរងគ្រោះផ្ទាល់នៃមណ្ឌលសកម្មភាពកំចាត់មីន YEMAC ហើយមិនបានសមាហរណកម្មជាមួយកម្មវិធីពិការភាព សុខភាព ឬ ការផ្តួចផ្តើម អភិវឌ្ឍន៍នានានៅក្នុងប្រទេសទេ។ នៅក្នុងខែឧសភា ឆ្នាំ ២០០៩ នាយក YEMACបាននិយាយថា កម្មវិធីជំនួយជនរងគ្រោះ ដំណើរការតែឯង ដោយសារមានបញ្ហាមូលនិធិធ្ងន់ធ្ងរ។

ហេតុផលចម្បងរបស់យ៉េម៉ែនដើម្បីក្លាយជាផ្នែកមួយនៃប្រទេស២៦ ដោយមានចំនួនអ្នករស់រានដ៏ច្រើនសន្ធឹក ហេតុដូច្នេះហើយក៏ជាការទទួលខុសត្រូវដ៏មហាស្វារ្យដែលត្រូវធ្វើ តែក៏មានតម្រូវការនិងសេចក្តីរំពឹងទុកដ៏មហិមាសម្រាប់ជំនួយផងដែរ ដើម្បីបង្កើនការទទួលបានការគាំទ្រហិរញ្ញវត្ថុរបស់អន្តរជាតិ។ ទោះយ៉ាងណា នៅក្នុខែឧសភា ឆ្នាំ ២០០៩ YEMAC បាននិយាយថា

មូលនិធិអន្តរជាតិលើប្រតិបត្តិការកម្មវិធីជំនួយជនរងគ្រោះបានធ្លាក់ចុះ ហើយមូលនិធិជាតិក៏មានក៏រិតផងដែរ។ ថវិកាបំរុងទុកគ្រាន់តែជាផ្នែកតូចមួយនៃថវិកាទាំងមូលនៃមណ្ឌលសកម្មភាពកំចាត់មីន។ ហើយគ្មានមូលនិធិអន្តរជាតិត្រូវបានបំរុងទុកសម្រាប់ជំនួយជនរងគ្រោះទេតាំងពីឆ្នាំ ២០០៧ មកនោះ។ នៅក្នុងឆ្នាំ ២០០៨ ដល់ ២០០៩ មូលនិធិរបស់រដ្ឋាភិបាលផ្តល់ដល់ YEMAC ត្រូវបានកាត់៥០%ដោយសារសេដ្ឋកិច្ចធ្លាក់ចុះ។ យោងលើ YEMAC ការកាត់បន្ថយថវិកាជាគ្រឿងសំគាល់សម្រាប់ការដោះមីន។

ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីអនុវត្តផែនការសកម្មភាពទីក្រុងណៃរូប៊ី យេម៉ែនបានបង្ហាញទិសដៅឆ្លាត (SMART) របស់ខ្លួននានានៅក្នុងខែវិច្ឆិកាឆ្នាំ២០០៥។ ហើយផែនការលំអិតបានធ្វើនៅក្នុងឆ្នាំ២០០៧។ ហើយបានកំណត់អោយអនុវត្តកម្មវិធីជាបួនដំណាក់កាល ដែលបានចាប់ផ្តើមតាំងពីឆ្នាំ ២០០១ មកម្ល៉េះ។ នៅក្នុងឆ្នាំ ២០០៩ YEMAC បាននិយាយច្រំដែលថា គ្មានហេតុផលដើម្បីផ្លាស់ប្តូរកម្មវិធីទេព្រោះ" យើងគិតថាវាជាវិធីសាស្រ្តល្អជាក់ស្តែងសំរាប់អ្នករស់រាន" យេម៉ែននៅតែបន្តទទួលបានសមិទ្ធិផលតិចជាងគោលដៅដែលដាក់ចេញជួយដល់ប្រជាជន ៥០០ នាក់ក្នុងមួយឆ្នាំ ( ហើយ២០០០នាក់នៅក្នុងឆ្នាំ២០០៥-២០០៩) ហើយនៅក្នុងបីដំណាក់កាលដំបូងជួយដល់ប្រជាជន ១៦៣៨ នាក់តាំងពីឆ្នាំ២០០១មក។ អ្នករស់រានតិចជាង៥០០នាក់ បានទទួលការគាំទ្រក្នុងការសមាហរណកម្មសេដ្ឋកិច្ច[២៦]។ ចម្លើយអ្នករស់រានហាក់ដូចជាបញ្ជាក់ផងដែរថាមជ្ឈការភាគច្រើនផ្តោតលើកម្មវិធីវេជ្ជសាស្រ្ត មិនបានបំពេញតម្រូវការផ្សេងៗរបស់គេទេ។ ១៥% បាននិយាយថា តម្រូវការរបស់គេត្រូវបានយកទៅពិចារណានៅពេលកំណត់អាទិភាពជំនួយជនរងគ្រោះនានា។

ទិសដៅមួយចំនួនពាក់ព័ន្ធទៅនឹងការងារត្រូវបានអនុវត្តដោយក្រសួងនានាដូចជា ការប៉ាន់ប្រមាណពីវិស័យសុខភាព និងការស្តារនីតិសម្បទា ការអនុវត្តនីយុទ្ធសាស្រ្តពិការភាព និង ការបង្កើតមណ្ឌលហ្វឹកហ្វឺនវិជ្ជាជិវៈ។ ទោះយ៉ាងណា YEMAC មិនដែលរាយការណ៍អំពីរឿងទាំងនេះទេ ការលើកឡើងនៅក្នុងឆ្នាំ២០០៨ថា ខ្លួន"ទទួលខុសត្រូវតែឯងក្នុងការធ្វើអោយសម្រេចបាននូវទិសដៅឆ្នាំ ២០០៥-២០០៩ "[២៧]។ ការសម្របសម្រួលជាមួយក្រសួង និង អង្គការនានានៅមានកំណត់លើការបញ្ជូនអ្នករស់រាន។ ទោះយ៉ាងណាក៏ដោយ ការប៉ាន់ប្រមាណជាអន្តរជាតិជាច្រើនបានជំរុញអោយ YEMAC សហការណ៍ជាមួយកម្មវិធីសង្គម និង កម្មវិធីអភិវឌ្ឍន៍ផ្សេងៗទៀតអោយបានច្រើនឡើង[២៨]។

ជាច្រើនឆ្នាំកន្លងមក ការសហការរបស់ YEMAC ជាមួយស្ថាប័នផ្សេងៗបានធ្លាក់ចុះយ៉ាងខ្លាំង។ គណកម្មាធិការទីប្រឹក្សាជំនួយជនរងគ្រោះរបស់ YEMAC ខ្លួនឯង ដែលមុនឆ្នាំ ២០០៥ ជាស្ថាប័នសកម្មដែលមានទាំងអង្គការ និង ដៃគូពាក់ព័ន្ធនានា។ ការចាប់ផ្តើមការធ្លាក់ចុះដំបូងនៃការចូលរួមអង្គការរហូតដល់ចំណុចទាបនោះដោយថា ពួកគេលែងត្រូវបានអញ្ជើញឱ្យចូលរួមតទៅទៀតនៅក្នុងឆ្នាំ២០០៧។ ទីពីរការចាប់ផ្តើមជួបគ្នា"នៅពេលចាំបាច់ប៉ុណ្ណោះ" ដែលមិនប្រក្រតីយ៉ាងខ្លាំង។ គណកម្មាធិការមិនបានធ្វើសេចក្តីសំរេចចិត្តទេ ឬ សមត្ថភាពធ្វើគោលនយោបាយទេ។ ការគ្រប់គ្រងមជ្ឈការរបស់ YEMAC មានតាំងពីឆ្នាំ២០០៥មកម្ល៉េះ ហើយក៏បានបង្ករការលំបាកសម្រាប់អង្គការដើម្បីទទួលបាននូវមូលនិធិឯករាជសម្រាប់គំរោងជំនួយជនរងគ្រោះ/ពិការភាព និងបានបណ្តាលអោយអង្គការមួយចំនួនចាកចេញ[២៩]។

មាន៤៤%បានដឹងថា គេដឹងថានរណាទទួលខុស ត្រូវការសម្របសម្រួលជំនួយជនរងគ្រោះ ហើយ២៧% បានគិតថាការសម្របសម្រួលជាមួយអង្គការបានល្អប្រសើរឡើងតាំងពីឆ្នាំ ២០០៥មក ហើយ ២២% បានរាយការណ៍ ថា មានកិច្ចសហការច្រើនជាមួយវិស័យពិការភាព។ មានតែ៧%បានកិតថា អ្នករស់រាន ឬ តំណាងរបស់គេបានត្រូវបញ្ចូលក្នុងការសម្របសម្រួលជំនួយជនរងគ្រោះ។ អ្នកអនុវត្តបានយល់ស្របថាៈ ៧៥% ឃើញថាមិនមានការប្រសើរលើកិច្ចសហការជំនួយជនរងគ្រោះ ឬការសម្របសម្រួលរបស់រដ្ឋាភិបាលជាមួយអង្គការទេ។ គ្មានអ្នកអនុវត្តណាម្នាក់បានគិតថាតម្រូវការរបស់អ្នករស់រានត្រូវបានយកទៅ

ពិចារណាទេនៅពេលធ្វើផែនការ ឬបញ្ចូលអ្នករស់រាននៅក្នុងការធ្វើផែនការ។

គេគួរកត់សំគាល់ថា ជោគជ័យ YEMAC ស្ទើរតែទាំងអស់ពឹងផ្អែកទាំងស្រុងទៅលើកិច្ចប្រឹងប្រែងរបស់ខ្លួន ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រងជាន់ខ្ពស់របស់ខ្លួនដែលបានធ្វើការកត់សំគាល់នៅក្នុងការជម្លៀសឆ្នាំ ២០០៥[៣០]។ ហើយនេះក៏បានទទួលស្គាល់ដោយ YEMAC ខ្លួនឯងនៅក្នុងឆ្នាំ ២០០៩ ផងដែរ ដែលបាននិយាយថា ប្រធានរបស់ YEMAC នៃនាយកដ្ឋានជនរងគ្រោះខ្វះសមត្ថភាព ហើយចាំបាច់ត្រូវការកាគាំទ្រសកម្មថែមទៀត។ គេបាននិយាយថា សមត្ថភាពរបស់ក្រសួងផ្សេង

យេម៉ែនបានសកម្មខ្លាំងឡើងលើបញ្ហាពិការភាពដោយសារកំណើនសមត្ថភាពរបស់ SFD និង ដោយសារគំរោងគាំទ្ររបស់ធនាគារពិភពលោកដើម្បីអភិវឌ្ឍន៍វិស័យពិការភាព។ SFD ត្រូវបានពិចារណាជាតួអង្គមួយនៃបណ្តាញកាត់បន្ថយភាពក្រីក្រមានប្រសិទ្ធិភាពបំផុតនៅក្នុងតំបន់ ហើយជាស្ថាប័នសារធារណតែមួយគត់ដែលគាំទ្រទាំងកំណែទម្រង់គោលនយោបាយ និងផ្តល់សេវាសម្រាប់ពិការភាព។ ហើយក៏មានយន្តការសម្របសម្រួលពិការភាពឯទៀតៗដែរ ដូចជាមូលនិធិស្តារនីតិសម្បទា និងការថែទាំជានពិការ(មូលនិធិពិការភាព) សហជីពពិការ និង អង្គការជន ពិការជាច្រើនទៀតដែលសម្របសម្រួលបានល្អណាស់។ ទោះយ៉ាងណា គេខ្វះធនធានមនុស្ស និង ការគាំទ្រពីរដ្ឋាភិបាល។ ការបញ្ចប់សព្វគ្រប់នូវផែនការយុទ្ធសាស្ត្រពិការភាពបានជិតកើតមានតាំងពីយូរមកហើយ តាំងពីកំណែថ្មីលើកទីមួយបានបញ្ជូនទៅនាយករដ្ឋមន្ត្រីនៅក្នុងឆ្នាំ ២០០៥ ហាក់ដូចជា ខ្វះខាតដោយសារកង្វះការវិភាគ ហ្មត់ចត់អំពីស្ថានភាព។

YEMAC បាននិយាយនៅក្នុងឆ្នាំ២០០៩ថា ខ្លួនបានព្យាយាមសុំកិច្ចសហប្រតិបត្តការពីធនាគារពិភពលោក និង SFD តែគ្មានភាពប្រកដប្រជាជាក់លាក់នៅអនាគតដ៏ខ្លីនោះទេ។ ហើយបានបន្ថែមទៀតថា SFD និង មូលនិធិពិការ ភាពជួយតែអ្នកដែលចុះឈ្មោះជាមួយគេ ហើយថាមានតែអ្នករស់រានតិចតួចប៉ុណ្ណោះបានចុះឈ្មោះ។ អង្គការជាច្រើន បានបញ្ចេញនូវចំណាប់អារម្មណ៍ចំពោះ YEMAC ក្នុងការបញ្ចូលអ្នករស់រានពីមីន/កាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមទៅក្នុងសកម្មភាពរបស់ខ្លួនថែមទៀត ជាពិសេសសកម្មភាពសេដ្ឋកិច្ចនិងសង្គម. នៅក្នុងឆ្នាំ២០០៨ YEMAC បានរាយការណ៍ថា ខ្លួនមានបំណងបិតនូវកម្មវិធីជំនួយជនរងគ្រោះនៅ ត្រឹមឆ្នាំ ២០១៤ តែមិនច្បាស់ថាតើមានយន្តការអន្តរកាលមាននៅនឹងកន្លែងហើយឬនៅ[៣១]។

## សេចក្តីសន្និដ្ឋាន

កម្មវិធីជំនួយជនរងគ្រោះរបស់ YEMAC បានផ្តល់ផលប្រយោជន៍ដល់អ្នករស់រាន អាចនាំឱ្យបានសម្រេចគោលដៅ តែទំហំភូមិសាស្ត្រ និង កំរិតនៃកម្មវិធីវាចង្អៀតខ្លាំងពេក។

- មិនមានការផ្លាស់ប្តូណាមួយត្រូវបានធ្វើឡើងលើកម្មវិធី YEMAC ដើម្បីគ្របដណ្តប់អោយបានច្រើនថែមទៀតលើតម្រូវការប្លែកៗជាច្រើនរបស់អ្នករស់រាននោះទេ។
- សកម្មភាពសមាហរណកម្មសេដ្ឋកិច្ចឡើងវិញ គ្មានការកាំទ្រពេញលេញ។
- ការចាកចេញរបស់អង្គការអន្តរជាតិ ដែលបានមើលឃើញយ៉េម៉ែនថាជាកន្លែងពិបាកធ្វើការ ហើយសុវត្ថិភាព ហិរញ្ញវត្ថុសម្រាប់ការងារ បានប៉ះពាល់យ៉ាងខ្លាំងដល់សកម្មភាពជំនួយជនរងគ្រោះ។
- គ្មានការភ្ជាប់ទំនាក់ទំនងគ្រប់គ្រាន់ទេ ជាមួយសង្គមស៊ីវិល និង វិស័យពិការភាពទូលំទូលាយ និង ជំនួយការសង្គម ឬវិស័យអភិវឌ្ឍន៍
- មូលនិធិជាតិសម្រាប់ជំនួយជនរងគ្រោះ និង សម្រាប់ពិការភាពមិនគ្រប់គ្រាន់ ហើយនៅក្នុងវិស័យស្តារនីតិសម្បទាត្រូវធ្វើអោយស្មុគស្មាញឡើងដោយការទទួលខុសត្រូវរបស់ក្រសួងនានា។

## ការស្នើរឡើងសម្រាប់ផែនការអនាគត

នៅពេលសួរអំពីការរំពឹងទុករបស់ពួកគេសម្រាប់ស្ថានភាពប្រាំឆ្នាំខាងមុខ ៤០% នៃអ្នករស់រានបានគិតថានឹងយ៉ាប់ជាងមុន ៣១%បានគិតថាវានឹងនៅតែដដែល ហើយ ២៩%បានគិតថានឹងប្រសើរឡើង។ ដើម្បីជួយឱ្យជំនួយសម្រាប់អនាគតល្អប្រសើរ គួរតែពិចារណាលើយោបល់ខាងក្រោម:

**តើអ្នកគិតថា ស្ថានភាពរបស់អ្នកនឹងក្លាយទៅជាយ៉ាងណានៅក្នុងប្រាំឆ្នាំទៀត?**




- ធ្វើវិមជ្ឈការកម្មវិធីជំនួយជនរងគ្រោះ ពង្រឹងសមត្ថភាពតាមដាន ហើយផ្តោតឡើវិញលើវិធីសាស្ត្រដែលបន្ថយ វិធីសាស្ត្រវេជ្ជសាស្ត្រ។
- គាំទ្រថែមទៀត រកមូលនិធិ(អន្តរជាតិ) សម្រាប់សមាហរណកម្មសេដ្ឋកិច្ចឡើងវិញ និងធានាថាអ្នករស់រានត្រូវបានបញ្ជូនជាប្រព័ន្ធទៅរកសេវាកម្មផ្សេងៗ។
- បញ្ចូលជំនួយជនរងគ្រោះនិងបទពិសោធន៍ទូលំទូលាយរបស់ YEMAC នៅក្នុងយុទ្ធសាស្ត្រពិការភាព សុខភាព និង យុទ្ធសាស្ត្រអភិវឌ្ឍន៍។ ហើយអោយអ្នករស់រានចូលរួមនៅក្នុងកម្មវិធីដែលមានស្រាប់និង ធានាឱ្យមានសកម្មភាពជំនួយជនរងគ្រោះគ្រប់គ្រាន់នៅYEMAC នៅក្នុងពេលឥឡូវនេះ។
- ធានាថា អ្នករស់រានទទួលភាពស្របច្បាប់សម្រាប់កម្មវិធីជនពិការ ឬ ក្រុមជនងាយរងគ្រោះ ជាឧទាហរណ៍តាមរយៈ កម្មវិធី SFD
- ធានាបញ្ចូលនូវតម្រូវការរបស់អ្នករស់រានទៅក្នុងយុទ្ធសាស្ត្រពិការភាពស្ថិតក្រោមការអភិវឌ្ឍន៍
- លៃបំរុងទុកមូលនិធិជាតិអោយបានគ្រប់គ្រាន់សម្រាប់ជំនួយជនរងគ្រោះ និង ពិការភាពអោយបានច្រើនថែមទៀត
- បញ្ចូលអ្នករស់រានច្រើនថែមទៀតទៅក្នុងជំនួយជនរងគ្រោះជាប្រព័ន្ធ ក៏ដូចជាទៅក្នុងការធ្វើផែនការពិការភាពទូទៅ និង ការអនុវត្តន៍
- បង្កើនអន្តរសកម្មភាពជាមួយសង្គមស៊ីវិលដោយធានានូវឯករាជ្យភាពរបស់ខ្លួន។

**សម្តីជនរងគ្រោះផ្ទាល់....**

អ្នកឆ្លើយបានពិពណ៌នាខ្លួនគេថាជា:អ្នកជម្ងឺ, ទទួលការឈឺចាប់គ្រប់ យ៉ាង, ធ្លាក់ទឹកចិត្ត, មានឆន្ទះមុតមាំ, បានប្តេជ្ញា ជំនះលើអនក្ខរភាព, ជាអ្នកអភិរក្ស, អន្ទះសារ, មានមហិច្ឆតា និង ជាអ្នកតស៊ូ។

**សម្តីជនរងគ្រោះផ្ទាល់....**

អាទិភាពចម្បងសម្រាប់ជំនួយការជនរងគ្រោះ សម្រាប់រយៈពេល៥ឆ្នាំខាងមុខ :

- យកចិត្តទុកដាក់ចំពោះយើង និង សម្របសម្រួលជាមួយយើង
- បង្កើនជីវភាពរស់នៅដល់អ្នករស់រាន
- ប្រមូលព័ត៌មានពីពួកយើងនិង សមាហរណកម្មពួកយើងទៅក្នុងសង្គម
- ផ្តល់ការថែទាំបន្ត
- ផ្តល់ការងារ និងផ្ទះសម្បែងដល់យើង
- ផ្តល់ការហ្វឹកហ្វឺន និង ស្តារនីតិសម្បទា
- ផ្តល់អវៈយវៈសិប្បនិម្មិតឱ្យនៅជិតផ្ទះ
- ផ្តល់អោយយើងនូវឱកាសការងារកាន់តែប្រសើរ

**សម្តីជនរងគ្រោះផ្ទាល់....**

ប្រសិនបើប្រទេសនានាពិតជាយកចិត្តទុកដាក់ដល់អ្នករស់រានមែនគេគួរតែ:

- ប្រសិនបើគេពិតជាអញ្ចឹងមែន ។ ខ្ញុំសូមឆ្លើយសំណួរនេះ។
- គាំទ្រសមាគមន៍អ្នករស់រាន [YALS] ដូចនេះគេអាចជួយយើងបានច្រើន
- សូមផ្តល់សិទ្ធិពេញលេញដល់អ្នករស់រាន
- គេមិនធ្វើទេ។ តែខ្ញុំប្រាថ្នាអោយគេគួតែធ្វើ
- ផ្តល់អោយយើងនូវចំណូលសមរម្យ
- សូមធានារ៉ាប់រង និង ស្មោះត្រង់លើការបារម្ភរបស់គេ
- ផ្តល់អោយយើងនូវឱកាសទទួលបានការងារ
- បង្កើនស្ថានភាពសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់ពួកគេ
- សូមផ្តល់អោយពួកគេនូវសិទ្ធិនៅក្នុងវិស័យការងារនិងឱ្យពួកគេចូលរួមនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត
- ជួយអោយយើងប្រកបរបរចិញ្ចឹមជីវិត
- ចុះមកសួរសុខទុក្ខ និង យកតម្រូវការរបស់យើង ទៅពិចារណាផង

**សម្តីជនរងគ្រោះផ្ទាល់....**

មតិយោបល់ផ្សេងៗដែលបានបញ្ចេញឆ្លើយតបនៅក្នុងការស្រាវជ្រាវ និង អ្នកឆ្លើយខ្លះជ្រើសរើសបញ្ចូលយោបល់អំពីសេវា ដូចជា:

**យ៉ាហ៊ីយ៉ា អាប់ឌូ មូហាម៉ាត់** ចូលចិត្តទៅ រកប្រទាលនៅភ្នំហើយគាត់ជាន់មីនដែលបណ្តាលឱ្យដាច់ជើងម្ខាងគាត់និយាយថា :

*" ខ្ញុំបានទទួលតែការថែទាំផ្ទាំពេទ្យបឋមប៉ុណ្ណោះ គ្មានការតាមដានទេ ។ ១០ឆ្នាំក្រោយមក ខ្ញុំបានធ្វើដំណើរប្រាំបី ម៉ោងទៅសាណាអា ដើម្បីទៅយកជើងសិប្បនិម្មិតដែល មានតម្លៃ ៥០០០០ រីយ៉ាល (២៥០ដុល្លា) ។ ខ្ញុំចង់ឱ្យសេវាដូចនេះនៅជិតផ្ទះហើយមិនបង់ប្រាក់" ។*

**សាលេហា ប៊ិញ មូហាម៉ាត់** មេម៉ាយអាយុ ៧២ ឆ្នាំ បានកត់សំគាល់ថា : *"ខ្ញុំរបួសពេលដែលខ្ញុំឃ្វាលចៀម នៅក្នុងឆ្នាំ ១៩៨២ ខ្ញុំបានទទួលការឈឺចាប់ពីការឈឺក្បាល និង មើលមិនសូវឃើញ។ ជាស្ត្រីម្នាក់ ខ្ញុំមិនបានទទួលការ គាំទ្រដែលខ្ញុំត្រូវការទេ។ ខ្ញុំបានមានអារម្មណ៍ថា បុរសមានឱកាសច្រើនជាង " ។*

**អាម៉ាត់ អាអឺ** បានបាត់បង់ជើងទាំងពីររបស់គាត់ នៅពេលគ្រោះថ្នាក់ជាន់មីនប្រឆាំងមនុស្ស នៅពេលគាត់ធ្វើជាទាហ៊ាន ។ គាត់រស់នៅតំបន់ភ្នំច្រើននៅ អាល់ដាលេ គាត់បាននិយាយថា: *"ខ្ញុំបានទទួលរទេះកង់បី តែខ្ញុំមិនអាចប្រើវានៅក្នុងតំបន់នេះទេ ខ្ញុំមានអារម្មណ៍ខ្សោយណាស់ ដោយខ្ញុំមិនអាចធ្វើចលនាបាន ហើយសេវាក៏ទៅមិនដល់ទៀត" ។*

**កាមីលា** ជាអ្នកសំភាសន៍ម្នាក់ បានបន្ថែមថា: *"អ្នករស់រានជាបុរសភាគច្រើនបំផុតមានគ្រួសារធំគាំទ្រ តែក៏ពិបាករកចំណូលណាស់ដែរ។ ស្ត្រីអ្នករស់រាន ដែលបាន សំភាសន៍ ជាទូទៅជាអនុវជន ហើយបានរបួសនៅពេលរកប្រទាល។ អ្នករស់រានទាំងអស់បានឃើញថា វាអស់កម្លាំង និងចុះសោហ៊ុយ ខ្លាំងពេលទៅការិយាល័យប្រៃយណីយ៍ ដើម្បីយកប្រាក់សោធនបន្តិចបន្តួចនោះ។ ហើយគេគិតថាអ្នកនៅជនបទតំបន់ដាច់ស្រយ៉ាល មិនបានទទួលសេវាពីនរណាទេ។ បើទោះជាអ្នករស់រានបាននិយាយថា គេត្រូវការសេវាសុខភាព សេវាអប់រំ សេវាសង្គម និង សេវាគាំទ្រផ្លូវចិត្តក៏ដោយ តែអ្វីដែលគេចង់បានបំផុតនោះគឺ ការងារសមរម្យទៅនឹងសមត្ថភាពពិការភាព របស់គេ និង ដើម្បីរស់នៅក្នុងភាពថ្លៃថ្នូ និងមានការគោរពពីសហគមន៍" ។*

# Yemen

[1] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 749; and ICBL, *Landmine Monitor Report 2004*, Washington, DC, October 2004, p. 866.
[2] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 749.
[3] UNDP, "2008 Statistical Update – Yemen," http://hdrstats.undp.org/en/countries/data_sheets/cty_ds_YEM.html, accessed 18 July 2009; and UNDP, *Human Development Report 2004: Cultural Liberty in Today's Diverse World*, New York, 2004, p. 141.
[4] World Bank (WB), "Gross national income per capita 2008, Atlas method and PPP," 1 July 2009, http://siteresources.worldbank.org/DATASTATISTICS/Resources/GNIPC.pdf; and UN Statistics Division, "Per capita GNI at current prices – US Dollars,"http://data.un.org/Data.aspx?d=SNAAMA&f=grID%3A103%3BcurrID% 3AUSD%3BpcFlag%3A1, accessed 18 July 2009.
[5] CIA, *The World Factbook – Yemen*, 2008, https://www.cia.gov/library/publications/the-world-factbook/geos/YM.html; and 2004, http://www.umsl.edu/services/govdocs/wofact2004/geos/ym.html, accessed 18 July 2009.
[6] WHO, "Detailed Database Search: Yemen," http://apps.who.int/whosis/data/Search.jsp?indicators=%5bIndicator%5d.%5bHSR%5d.Members,accessed 18 July 2009.
[7] WHO, "World Health Statistics 2009," Geneva, 2009, pp. 95, 102; The WHO estimates that countries with less than 23 healthcare professionals (physicians, nurses and midwives) per 10,000 population are unlikely to achieve adequate coverage.
[8] UN, Convention [on the Rights of Persons with Disabilities] & Optional Protocol Signatories & Ratification," http://www.un.org/disabilities/countries.asp?id=166, accessed 18 July 2009.
[9] [9] CIA, *The World Factbook – Yemen*, 2008, https://www.cia.gov/library/publications/the-world-factbook/geos/YM.html; UNDP, "Millennium Development Goals in Yemen," 26 March 2009, http://www.undp.org.ye/yemen_mdgs.php, accessed 18 July 2009.
[10] See Yemen chapter in *Landmine Monitor Reports*, 1999-2008; and "Final Report of the Sixth Meeting of States Parties/Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 217-224.
[11]WB, "Yemen, an Integrated Approach to Social Sectors – Towards A Social Protection Strategy," Sana'a, 29 June 2007, pp. 31-32.
[12] ICBL, *Landmine Monitor Report 2005*, Ottawa, October 2005, p. 622; notes from victim assistance session at YEMAC/ICBL workshop, Sana'a, 3 February 2007.
[13] This included 10 people who had given their occupation prior to the incident, indicating that they were now also unemployed
[14] 2% non-response rate.
[15] Article 7 Report (for period from 31 March 2008 to 31 March 2009), Form I, 31 March 2009.
[16] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 758; and ICBL, *Landmine Monitor Report 2007*, Ottawa, October 2007, p.745.
[17] 6% non-response rate.
[18] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 757; and Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p. 218.
[19] B. Pound *et al.*, "Departure of the Devil: Landmines and Livelihoods in Yemen," *GICHD*, Geneva, 2006, p. 33.
[20] "Final Report of the Sixth Meeting of States Parties/Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p.220.
[21] 11% non-response rate
[22] "Final Report of the Sixth Meeting of States Parties/Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p.221; and ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 757.
[23] B. Pound *et al.*, "Departure of the Devil: Landmines and Livelihoods in Yemen," *GICHD*, Geneva, 2006, p. 33.
[24] "Final Report of the Sixth Meeting of States Parties/Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p.221.
[25] [25] WB, "Yemen, an Integrated Approach to Social Sectors – Towards A Social Protection Strategy," Sana'a, 29 June 2007, pp. 55, 132; and ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, pp. 757, 759
[26] Article 7 Report (for period from 31 March 2008 to 31 March 2009), Form I, 31 March 2009.
[27] ICBL, *Landmine Monitor Report 2008*, Ottawa, October 208, p. 759.
[28] B. Pound *et al.*, "Departure of the Devil: Landmines and Livelihoods in Yemen," *GICHD*, Geneva, 2006; and GICHD, "Mid-Term Outcome Evaluation for Strengthening National Capacity for Mine Action in Yemen-Phase II," Geneva, 2005
[29]ICBL, *Landmine Monitor Report 2005*, Ottawa, October 2005, p. 622; ICBL, *Landmine Monitor Report 2006*, Ottawa, July 2006, p. 795; ICBL, *Landmine Monitor Report* 2008, Ottawa, October 2008, p. 759; and interview with two NGO representatives in November 2008.
[30] GICHD, "Mid-Term Outcome Evaluation for Strengthening National Capacity for Mine Action in Yemen-Phase II," Geneva, 2005, p. 24; and ICBL, *Landmine Monitor Report 2005*, Ottawa, October 2005, pp. 622-623
[31]Response by Head of VA Department, YEMAC, Sana'a, 3 August 2008.